ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២០

នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងបន្តសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុវត្តយល់ព្រមលើពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការហាមឃាត់អាវុធនុយក្លេអ៊ែរ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីមួយវិសោធនកម្មកិច្ចព្រមព្រៀងស្តីពី ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារដើម្បីអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ី



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

អាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការវិនិយោគ រវាងបណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់ ពីរដ្ឋសភា និងបានចាត់ចែងតាមនីតិវិធី

- បានទទួលព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច និងរបាយការណ៍ ចំនួន១១៦ច្បាប់ និងបានចាត់ចែងតាមនីតិវិធី

- បានធ្វើកំណត់បង្ហាញអនុក្រឹត្យ ប្រកាស និងរបាយការណ៍ចំនួន១១ច្បាប់

- កំពុងសិក្សាស្រាវជ្រាវផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៧ច្បាប់។

**២- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ចូលរួមគោរពវិញ្ញាណក្ខន្ធសព និងចូលរួមក្នុងពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន០៨លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀង ចែកអំណោយ និងអប់រំផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩(Covid-19) ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១២០លើក

- អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ទៅប្រគល់ជូនអាជ្ញាធរនៅសង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក សង្កាត់បាក់ខែង សង្កាត់កោះដាច់ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ (Covid-19)

- បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ

ដើម្បីដោះស្រាយចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន០២ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០៤ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣ករណី តម្កល់ទុកមិនចាត់ការចំនួន០១ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបជាព័ត៌មានចំនួន០១ករណី

- បានចូលរួមគាំទ្របរិច្ចាគថវិកាជូនមូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅ នៅបណ្ណាល័យព្រឹទ្ធសភាចំនួន២៧នាក់ ព្រមទាំងបានអនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន០៤ក្បាល និងសងវិញចំនួន០៥ក្បាល

- បានប្រគល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជូនដល់បណ្ណាល័យរដ្ឋសភា បណ្ណាល័យគ.ជ.ប ក្រសួងការពារជាតិ និងជូនដល់សិក្ខាកាមចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយសៀវភៅរបស់ ឯកឧត្តមនាយឧត្តមសេនីយ៍ ចៅ កិរុណ ចំនួន៣,០៣៦ក្បាល សម្រាប់សិក្សាស្រាវជ្រាវ

- បានផលិតទស្សនាវដ្ដីប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ ចំនួន១,២០០ក្បាល

- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សារបស់អគ្គនាយកដ្ឋានសម្ភារបច្ចេកទេស និងនាយទាហានទទួលបន្ទុកផ្នែកច្បាប់ មកពីក្រសួងការពារជាតិនៅព្រឹទ្ធសភាចំនួន០២លើក មានសិក្ខាកាមចំនួន១៥០នាក់។

**៣- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទីកន្លែង និងផ្ដល់សេវាក្នុងពិធីសម្ដែងការគួរសម រវាងសម្ដេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្ដីទីនៃព្រះរាជាណាចក្រកម្ពុជា ជាមួយប្រតិភូនិស្សិតអាហារូបករណ៍អូស្ត្រាលី និងនូវែលសេឡង់ចំនួន២៧នាក់

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ចូលរួមប្រជុំក្រុមភូមិសាស្ត្រនយោបាយតំបន់អាស៊ី-ប៉ាស៊ីហ្វិក(APG) ចូលរួមមហាសន្និបាតប្រចាំឆ្នាំនៃបណ្ដាញក្រុមសីលធម៌សមាជិកសភាប្រើប្រាស់ភាសាបារាំង និងចូលរួមប្រជុំមហាសន្និបាតវិសាមញ្ញលើកទី២០៦ នៃក្រុមប្រឹក្សាភិបាលសហភាពអន្តរសភា(IPU) តាមប្រព័ន្ធវីដេអូ

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៣ច្បាប់

- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មានស្តីពី សភានៅលើបណ្តាប្រទេសនានា ចំនួន៨៣ប្រធានបទ

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែវិច្ឆិកាចំនួន០១ច្បាប់

- បានផលិតព័ត៌មានច្បាប់ និងនយោបាយជាច្បាប់ជាតិ និងអន្តរជាតិចំនួន២០០អត្ថបទ

- បានទំនាក់ទំនងជាមួយដៃគូភាគីចិន អង្គការមូលនិធិអាស៊ី វិទ្យាស្ថានសាន់វ៉ាយស៍ ក្រុមហ៊ុនKOHA ក្រសួង និងស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានទទួលលិខិតចូលចំនួន៥៥១ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៦១ច្បាប់

- រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩(Covid-19)

- បន្តយកចិត្តទុកដាក់ការងារអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភាឱ្យ បានលឿនល្អ និងរលូន

- បន្តយកចិត្តទុកដាក់មជ្ឈដ្ឋានដែលនៅខ្សោយ និងសមត្ថភាពផលិតសេវានៅទាប

- បានប្រជុំពិនិត្យ និងពិភាក្សាគម្រោងបែងចែកកញ្ចប់ថវិកាឆ្នាំ២០២១ របស់ព្រឹទ្ធសភា

- បានប្រជុំពិនិត្យ និងពិភាក្សាលើការរៀបចំកសាង និងអនុវត្តថវិកាកម្មវិធីឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំការងារផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងពិនិត្យរបាយការណ៍អនុវត្ត កិច្ចលទ្ធកម្មឆ្នាំ២០២០ របាយការណ៍អនុវត្តកិច្ចលទ្ធកម្មរយៈពេល៨ឆ្នាំ បទបង្ហាញស្តីពី ការត្រួតពិនិត្យ ផែនការលទ្ធកម្មឆ្នាំ២០២០ និងផែនការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០២១

- បានប្រជុំពិនិត្យ និងពិភាក្សាការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំរៀបចំផែនការថវិកា និងសូចនាករសមិទ្ធកម្មក្នុងឆ្នាំ២០២១ ក្រោមកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានទំនាក់ទំនងបង់ពន្ធផ្លូវរថយន្តបម្រើការងារប្រចាំឆ្នាំ២០២០

- បានប្រជុំគណៈកម្មការរៀបចំគ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា នៅពាក់កណ្ដាលនីតិកាលទី៤

- បានប្រជុំការងាររៀបចំរបាយការណ៍វឌ្ឍនភាពសមិទ្ធកម្ម ផែនការសកម្មភាព(Map3) និងសូចនាករសមិទ្ធកម្ម (KPIs) នៃការអនុវត្តថវិកា៨ខែ ឆ្នាំ២០២០ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានប្រជុំពិនិត្យសេចក្ដីព្រាងផែនការសកម្មភាពរួម និងក្របខណ្ឌលទ្ធផលដំណាក់កាលទី៤ (CAP4) គណនេយ្យភាពសមិទ្ធកម្ម (២០២១-២០២៥)

- បានសិក្សាការរៀបចំវិទ្យាស្ថានសភាអាស៊ី(PCA) ដំណាក់កាលបន្ទាប់ពីវិទ្យាស្ថានសភាកម្ពុជា(PIC ) និងការរៀបចំ Legal Database របស់ព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្រប នឹងដំណាក់កាលថ្មី

- បានប្រជុំគណៈកម្មការតាំងស៊ុបក្នុងក្របខណ្ឌមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានសិក្សាស្រាវជ្រាវកសាងគោលការណ៍ស្ដីពី ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើផែនការសកម្មភាពបណ្ដុះបណ្ដាលរយៈពេល១០ឆ្នាំ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធ ដើម្បីរៀបចំកសាងគោលនយោបាយអភិវឌ្ឍធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានបើកប្រាក់បៀវត្សប្រចាំខែវិច្ឆិកា និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែវិច្ឆិកា ឆ្នាំ២០២០

- បង្កើន3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល ដើម្បីទ្រទ្រង់ដំណើរការថវិការហូតដល់ចុងឆ្នាំ២០២០

- បានរៀបចំតភ្ជាប់បណ្ដាញប្រព័ន្ធ (FMIS) បំពាក់សម្ភារ ការប្រើប្រាស់ និងប្រជុំតាមប្រព័ន្ធវីដេអូ(Zoom)

- បានធ្វើប័ណ្ណសម្គាល់ខ្លួន ប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន០៤ប័ណ្ណ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៣៤ច្បាប់

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន១៦វគ្គ មានសិក្ខាកាមចូលរួមចំនួន២៤៥នាក់

- ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារួមមានៈ ចំណេះដឹងជំនាញ ភាសាបរទេស ការដឹកនាំ/គ្រប់គ្រង និងបច្ចេកវិទ្យាព័ត៌មាន

- បានបន្តសាងសង់សាលប្រជុំថ្មីនៅខាងក្រោយសាលពិសេសកណ្តាល

- បានបាំងបន្ទប់ធ្វើឃ្លាំង និងធ្វើធ្នើដាក់សៀវភៅនៅបណ្ណាល័យ

- បានរៀបចំកែសម្រួលបង្រួមសួនច្បារ ដើម្បីធ្វើចំណតរថយន្តថ្មី នៅខាងមុខសាលខាងជើង និងសាលពិសេស

- បានចាក់ក្រាលបេតុងនៅពេងរថយន្តក្រោមដើមជ្រៃនៃបរិវេណព្រឹទ្ធសភា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានាចំនួន១២ប្លង់ ព្រមទាំងកាត់តម្រឹមមែកឈើចំនួន០៤លើក

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យដណ្តើរយន្ត និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៧៨គ្រឿង/លើក

- បានចុះត្រួតពិនិត្យ ប្រព័ន្ធណេតវើក ប្រព័ន្ធអ៊ីនធើណេត និងជួសជុលម៉ាស៊ីនកុំព្យូទ័រ Smart Phone ចំនួន៨៦គ្រឿង

- បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន៦៤ក្បាល

- បានប្រើប្រាស់ Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

## II-**លទ្ធផលការងារគាំទ្រលើមុខងារទាំង៥ៈ**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣២៥ច្បាប់

- បានរៀបចំចាត់ចែង ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៨លើក

- បានតុបតែងលម្អ និងតាំងពិព័រណ៍រូបភាពចំនួន០៤លើក

- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន២៧ច្បាប់ ស្មើនឹង៧៦នាក់

- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣៤២លើក

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣៩លើក មានអ្នកចូលរួមចំនួន៨១៧នាក់

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន៧៩សំណើ

- បានចែកទឹកអាល់កុល និងជែលលាងដៃសម្រាប់មេរោគតាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន៦,៩២៨ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៧១ក្បាល អស់ក្រដាសចំនួន១៣៥,៩៨៧សន្លឹក

- បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុង ចំនួន១៣២លើក ស្មើនឹង៣២៩នាក់

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចចំនួន០៤ច្បាប់

- បានផលិតវីដេអូព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter Youtube Facebook និងតាម Telegramចំនួន១,២០០លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤៨លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២២លើក

- បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ ទស្សនាវដ្ដី និងរាជកិច្ចចំនួន៧០ក្បាល និងព្រឹត្តិបត្រ កាសែតAKPចំនួន៣០ច្បាប់ ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ អ៊ុតក្របសៀវភៅ បិទប័ណ្ណខ្នង និងសងសៀវភៅចំនួន១២៥ក្បាល

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១១លើក។

**III-ទិសដៅការងារសម្រាប់ខែធ្នូ ឆ្នាំ២០២០**

- ត្រៀមប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១

- បញ្ចប់ការងារបំណាច់ឆ្នាំ២០២០ និងកំណត់ការងារអាទិភាពឆ្នាំ២០២១ របស់គ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី៤៖

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

៣-សេចក្តីព្រាងច្បាប់ស្តីពី មូលបត្ររដ្ឋ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពី ការទទួលស្គាល់ទៅវិញទៅមកលើការផ្តល់អាជ្ញាបណ្ណក្រុមអាកាសយានិក

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

៦.១-ពិធីសារទី៣ស្តីពី សិទ្ធិសហការលើជើងហោះហើរក្នុងស្រុកក្នុងវង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ

៦.២-ពិធីសារទី៤ស្តីពី សិទ្ធិហោះហើរកូដ័រមីណាល (Co-Terminal Rights) រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន

៧- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារ អនុវត្តកញ្ចប់សន្យាទី៩ និងទី១០នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារ ជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំពិធីជំនួបសវនាការរវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអង្គទូតនានា

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានា។ល។)

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធOnline ដើម្បីជានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-រៀបចំរបាយការណ៍ចំណូល ចំណាយថវិកាព្រឹទ្ធសភាប្រចាំឆ្នាំ២០២០ និងរៀបចំបែងចែកកញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ កម្រិតរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ត្រៀមរៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធីលើមូលដ្ឋានរចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋានទាំង៥

-បន្តសហការជាមួយក្រុមការងារFMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់និងបំពាក់សម្ភារប្រជុំតាមប្រព័ន្ធវីដេអូ(Zoom)

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតម្រូវការផ្សេងៗ

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងបរិវេណព្រឹទ្ធសភា

-ត្រៀមរៀបចំចាក់អ៊ុតកៅស៊ូថ្នល់នៅប៉ែកខាងជើងនៃបរិវេណព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) គ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-ត្រៀមបោះពុម្ពដំណាច់ឆ្នាំះ ទិនានុលេខន៍ ប្រតិទិន និងបោះពុម្ពឯកសារសំខាន់ៗផ្សេងទៀតសម្រាប់បម្រើជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមចូលរួមពិធីបុណ្យជាតិសំខាន់ៗ។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែវិច្ឆិកានេះ ទោះបីកម្ពុជាយើងជួបបញ្ហាប្រឈមនឹងព្រឹត្តិការណ៍៣វិច្ឆិកា និងព្រឹត្តិការណ៍សហគមន៍២៨វិច្ឆិកាក៏ដោយ ព្រឹទ្ធសភានៅតែបន្តការងារជាអាទិភាពលើមុខងារស្នូលទាំង៣របស់ខ្លួនប្រព្រឹត្តិទៅតាមការគ្រោងទុក ដោយបានរៀបចំ និងចាត់ចែងប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី៤។ ទន្ទឹមនឹងនេះមន្ត្រីរាជការ បានអមដំណើរសមាជិកព្រឹទ្ធសភា ចុះបំពេញការងារតាមមូលដ្ឋានដើម្បីសួរសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា បានយ៉ាងល្អប្រសើរ។ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងការប្រជុំអន្តរជាតិនានា តាមប្រព័ន្ធវីដេអូ (Zoom) បានដោយរលូន។ ក្រៅពីការងារជាអាទិភាពខាងលើអគ្គលេខាធិការដ្ឋាននៅតែបន្តយកចិត្តទុកដាក់បណ្តុះបណ្តាលលើកកម្ពស់សមត្ថភាព និងជំនាញរបស់មន្ត្រីរាជការឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

ដោយឡែកព្រឹទ្ធសភា ក៏បានចូលរួមពិធីថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា

ព្រះបរមរតនកោដ្ឋ និងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យនៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា រួមទាំងពិធីបុណ្យផ្សេងៗទៀតផងដែរ។

ការដ្ឋានពង្រីកផ្លូវ និងជួសជុលចំណតរថយន្ត បានដំណើរការដោយរលូន ទន្ទឹមនឹងការខិតខំដាំដើមឈើបន្ថែម ដើម្បីធ្វើឱ្យបរិស្ថានព្រឹទ្ធសភាស្អាត និងបៃតង (Clean and Green)។ សាលប្រជុំថ្មីមួយទៀតកំពុងត្រូវរៀបចំបង្ហើយកិច្ចការចុងក្រោយ ទន្ទឹមនឹងការខិតខំបាក់អ៊ុតកៅស៊ូថ្នល់តំបន់ខាងជើងឱ្យបានមុនដំណាច់ឆ្នាំ២០២០នេះ។

ថ្ងៃ[illegible] ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ